### តើខ្ញុំត្រូវទទួលជំនួយអាហាររបស់ខ្ញុំតាមរយៈ WASHCAP?

ក្រោមកាលៈទេសៈមួយចំនួន អ្នកអាចជ្រើសរើសទទួលអាហារមូលដ្ឋានជំនួសឱ្យ WASHCAP។ សូមទាក់ទង WASHCAP បើអ្នកមានសំណួរបន្ថែមអំពីការជ្រើសរើសយក។

### តើអ្នកត្រូវការដឹងអ្វីអំពីកាផ្ទេរអត្ថប្រយោជន៍អេឡិចត្រូនិច (EBT)?

- ប្រសិនបើអ្នកមានកាត EBT វ៉ាស៊ីនតោនរួចហើយ អ្នកអាចប្រើវា និងលេខសម្គាល់ផ្ទាល់ខ្លួន (PIN) បច្ចុប្បន្នរបស់អ្នក
- ប្រសិនបើអ្នកមិនមានកាត EBT ទេ អ្នកអាចស្នើយើងឱ្យផ្ញើកាតតាមសំបុត្រ។ កាតគួរតែទៅដល់ក្នុងពេល 5-7 ថ្ងៃធ្វើការ។
- អ្នកនឹងទទួលកូនសៀវភៅណែនាំជាមួយកាត EBT របស់អ្នក។



### តើអ្នកអាចឱ្យកាត EBT ទៅនរណាម្នាក់ដើម្បីទិញទំនិញសម្រាប់អ្នកបានទេ?

- អ្នកគួរតែកុំឱ្យកាត EBT ឬ PIN របស់ទៅអ្នកដទៃ។
- ដើម្បីអនុញ្ញាតឱ្យអ្នកដទៃទិញទំនិញសម្រាប់អ្នក សូមទូរស័ព្ទមក WASHCAP ដើម្បីស្នើទម្រង់បែបបទផ្តល់ការអនុញ្ញាតពីម្ចាស់កាត EBT ជំនួស។

### តើអ្វីជាសិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក?

- អ្នកមានសិទ្ធិស្នើសុំសវនាការ បើអ្នកមិនយល់ព្រមតាមសេចក្តីសម្រេចដែលយើងធ្វើអំពីជំនួយអាហាររបស់អ្នក។
- អ្នកត្រូវបានតម្រូវឱ្យរាយការណ៍ការផ្លាស់ប្តូរទាំងអស់ក្នុងស្ថានភាពរបស់អ្នកទៅកាន់បុគ្គលិករដ្ឋបាលសន្តិសុខសង្គម (SSA) របស់អ្នក។
- អ្នកក៏អាចទូរស័ព្ទមក WASHCAP តាមលេខ 1-877-380-5784 ដើម្បីដឹងថាតើការផ្លាស់ប្តូរទាំងនេះប៉ះពាល់ដល់ជំនួយអាហាររបស់អ្នកឬយ៉ាងណា។

Washington State
Department of Social & Health Services
Transforming lives

DSHS 22-480 CA (Rev. 4/18)

# WASHCAP

## គម្រោងពាក្យសុំរួមគ្នារដ្ឋវ៉ាស៊ីនតោន



## តើអត្ថប្រយោជន៍ WASHCAPមានអ្វីខ្លះ?

- ការសម្ភាសន៍របស់អ្នកសម្រាប់អត្ថប្រយោជន៍ SSI អាចជាការសម្ភាសន៍សម្រាប់ជំនួយអាហារ។
- យើងនឹងមិនស្នើឱ្យអ្នកបំពេញទម្រង់បែបបទជាច្រើនឡើយ។
- អ្នកអាចមានរយៈពេលបញ្ជាក់វែងជាង។
- អ្នកអាចមិនចាំបាច់ទៅការិយាល័យក្រសួងសេវាសង្គម និងសុខាភិបាល (DSHS)។
- អត្ថប្រយោជន៍អាហាររបស់អ្នកនឹងចូលទៅគណនីការផ្ទេរអត្ថប្រយោជន៍អេឡិចត្រូនិច (EBT)។ យើងនឹងផ្ញើកាតទៅអ្នកដើម្បីប្រើ នៅពេលអ្នកទិញគ្រឿងទេស។ កាត EBT ដំណើរការដូចគ្នានឹងកាតធនាគារ ឬកាតឥណពន្ធដែរ។

## តើខ្ញុំអាចទទួលជំនួយអាហារ WASHCAP ដោយរបៀបណា?

អ្នកនឹងទទួលបាន WASHCAP នៅពេលអ្នកត្រូវបានអនុម័តសម្រាប់ជំនួយអាហារ ហើយអ្នក៖

- ទទួលបាន SSI
- យ៉ាងហោចណាស់អាយុ 18 ឆ្នាំ
- មិនទាន់រៀបការ
- រៀបការរួច ប៉ុន្តែមិនកំពុងរស់នៅជាមួយប្តី ឬប្រពន្ធរបស់អ្នក
- មិនកំពុងរស់នៅជាមួយកូនរបស់អ្នកក្រោមអាយុ 22 ឆ្នាំ
- មិនកំពុងធ្វើការ និង
- រស់នៅម្នាក់ឯង ឬទិញ និងដោះស្រាយរឿងអាហាររបស់អ្នកដោយឡែកពីមនុស្សផ្សេងទៀតដែលរស់នៅជាមួយអ្នក។



## តើអ្នកអាចរាយការណ៍ការផ្លាស់ប្តូរដោយរបៀបណា?

- រាយការណ៍ការផ្លាស់ប្តូរទៅការិយាល័យសន្តិសុខសង្គម (SSA) តាមលេខ 1-800-772-1213។

## តើការផ្លាស់ប្តូរអ្វីខ្លះអ្នកត្រូវរាយការណ៍ទៅសន្តិសុខសង្គម?

- ប្រាក់ចំណូល
- ធនធាន
- ស្ថានភាពអាពាហ៍ពិពាហ៍
- ស្ថានភាពរស់នៅ

## តើពេលណាយើងនឹងពិនិត្យមើលករណីរបស់អ្នក?

- នៅពេល SSA ពិនិត្យមើលករណីរបស់អ្នក ជំនួយអាហារ WASHCAP របស់អ្នកក៏អាចបញ្ជាក់ឡើងវិញអំឡុងពេលការពិនិត្យមើលរបស់ SSA ផងដែរ។
- ប្រសិនបើ SSA មិនពិនិត្យមើលករណីរបស់អ្នកទេ យើងនឹងផ្ញើទម្រង់បែបបទទៅអ្នកដើម្បីបំពេញ និងប្រគល់មកវិញ មុនពេលអត្ថប្រយោជន៍របស់អ្នកបញ្ចប់។

## តើគម្រោងអាហារ WASHCAP គឺជាអ្វី?

WASHCAP គឺជាគម្រោងពាក្យសុំរួមគ្នារដ្ឋវ៉ាស៊ីនតោន។ វាគឺជាកម្មវិធីអាហារពិសេសមួយសម្រាប់មនុស្សមួយចំនួនដែលទទួលបាន SSI។

*សូមទូរស័ព្ទមក WASHCAP តាមលេខ*
*1-877-380-5784 បើអ្នកមានសំណួរណាមួយ។*